ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរសុខាភិបាល ខេត្តស្ទឹងត្រែង
ក្រុមលទ្ធកម្ម
លេខ : ០២៤ មសខ.លគ.១៧

សេចក្ដីជូនដំណឹង
ស្ដីពី
ការអញ្ជើញចូលរួមដេញថ្លៃ ការងារជួសជុលក្លោងទ្វារមន្ទីរសុខាភិបាល ជូនមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

មន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង នឹងដាក់ឱ្យដេញថ្លៃ ជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារ**ជួសជុលក្លោងទ្វារ ជូនមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង** ។

មន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង ដែលមានអាសយដ្ឋានភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ចាប់ពីថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១៧៧៦៣៧៣៧) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង០៨ម៉៣០ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨ម៉៣០ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ៣រោច ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៨
ប្រធានមន្ទីរសុខាភិបាល និងជា
ប្រធានក្រុមលទ្ធកម្ម

វេជ្ជ.អ៊ុង.សុវៀត

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ